# ការពិនិត្យមើលលើឯកសារស្រាវជ្រាវស្ដីពីការចូលរួមរបស់សមាជិកមហាវិទ្យាល័យក្នុងដំណើរការអន្តរជាតូបនីយកម្មឧត្ដមសិក្សា

## សេចក្ដីផ្ដើម

ដើមឡើយ អន្តរជាតូបនីយកម្មឧត្ដមសិក្សា គ្រាន់តែជាសកម្មភាព ឬកម្មវិធីដាច់ៗពីគ្នា (ទាក់ទងនឹងអន្តរជាតិ) ដែលបានអនុវត្តនៅតាមបណ្ដាគ្រឹះស្ថានឧត្ដមសិក្សាតែប៉ុណ្ណោះ។ ក៏ប៉ុន្តែនាពេលថ្មីៗនេះ វាត្រូវបានគេចាត់ទុកថាជា ដំណើរការរួមមួយដែលត្រូវបានអនុវត្តយ៉ាងទូលំទូលាយ និងមានលក្ខណៈជាយុទ្ធសាស្ត្រ និងតម្រូវឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានានៅក្នុងគ្រឹះស្ថានឧត្ដមសិក្សា ក្នុងនោះមានដូចជា ថ្នាក់ដឹកនាំ គ្រូបង្រៀន អ្នកស្រាវជ្រាវ និងបុគ្គលិករដ្ឋបាល ដែលជាទូទៅ ពួកគេភាគច្រើនមិនទាន់យល់ដឹងច្បាស់នៅឡើយទេថា តើដំណើរការទាំងនោះជាអ្វីឱ្យប្រាកដ? ឬ តើពួកវាគួរមានលក្ខណៈបែបណា ឬអាចមានលក្ខណៈអ្វីខ្លះនោះទេ? (Buckner and Stein 2020)។ មកទល់នឹងពេលនេះ ទោះបីមានការឱ្យនិយមន័យជាច្រើនទៅលើពាក្យ "អន្តរជាតូបនីយកម្មឧត្ដមសិក្សា" នេះក៏ដោយ ក៏មិនទាន់មានការទទួលស្គាល់ជារួមណាមួយនៅឡើយទេ។ ទោះជាយ៉ាងនេះក្ដី និយមន័យរបស់ Knight (2004, 11) ដែលបានពិពណ៌នាពាក្យនេះថាជា "ដំណើរការបញ្ចូលធាតុអន្តរជាតិ អន្តរវប្បធម៌ និងជាសាកលទៅក្នុងមុខងារបង្រៀន ការស្រាវជ្រាវ និងការផ្ដល់សេវាកម្មរបស់គ្រឹះស្ថានឧត្ដមសិក្សា" ត្រូវបានគេប្រើប្រាស់ញឹកញាប់ជាងគេ។ បន្ទាប់មក de Wit et al. (2015, 29) បានធ្វើការកែសម្រួលទៅលើនិយមន័យដើមរបស់ Knight (2004) ដោយបានកំណត់ន័យរបស់អន្តរជាតូបនីយកម្មឧត្ដមសិក្សា ថាជា "ដំណើរការដោយចេតនាក្នុងការបញ្ចូលធាតុអន្តរជាតិ អន្តរវប្បធម៌ និងជាសាកលទៅក្នុងមុខងារបង្រៀន ការស្រាវជ្រាវ និងការផ្ដល់សេវាកម្មរបស់គ្រឹះស្ថានឧត្ដមសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំ និងការស្រាវជ្រាវសម្រាប់និស្សិត និងបុគ្គលិក និងដើម្បីចូលរួមអភិវឌ្ឍសង្គមប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅ" ដើម្បីធ្វើឱ្យន័យរបស់ពាក្យនេះ មានលក្ខណៈបរិយាបន្នជាងមុន។ ការដែលកំណត់និយមន័យបែបនេះ ផ្ដោតសំខាន់លើចេតនារបស់គ្រឹះស្ថានឧត្ដមសិក្សា ក្នុងការធ្វើអន្តរជាតូបនីយកម្មតាមរយៈការបញ្ចូលធាតុអន្តរជាតិ អន្តរវប្បធម៌ និងជាសាកលទៅក្នុងមុខងារបង្រៀន ការស្រាវជ្រាវ និងការផ្ដល់សេវាកម្មរបស់ខ្លួន ដើម្បីបម្រើដល់កំណើនសេដ្ឋកិច្ច និងតម្រូវការសង្គមជាតិ។

លើសពីនេះ គេជឿថា ការធ្វើអន្តរជាតូបនីយកម្ម បាននាំមកនូវអត្ថប្រយោជន៍ជាច្រើនដល់គ្រឹះស្ថានឧត្ដមសិក្សា៖ វាអាចជួយធ្វើឱ្យគុណភាពកម្មវិធីសិក្សាកាន់តែប្រសើរឡើង បង្កើនការយល់ដឹងជាអន្តរជាតិ និងការចូលរួមជាសកលរបស់និស្សិត ទាក់ទាញបុគ្គលិកនិងនិស្សិតដែលមានទេពកោសល្យ និងជួយពង្រីកនិងពង្រឹងកេរ្តិ៍ឈ្មោះនិងចំណាត់ថ្នាក់អន្តរជាតិ របស់គ្រឹះស្ថានឧត្ដមសិក្សាឱ្យកាន់តែល្បីរន្ទឺ។ មិនតែប៉ុណ្ណោះ ការស្រាវជ្រាវនិងការផលិតចំណេះដឹងថ្មីៗ ការពង្រីកភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការបង្កើនប្រាក់ចំណូល ក៏តែងត្រូវបានរាយការណ៍ថាជាអត្ថប្រយោជន៍ចម្បងៗ នៃការធ្វើអន្តរជាតូបនីយកម្មឧត្ដមសិក្សាផងដែរ (Knight 1994, 2004)។ ហេតុនេះហើយ គ្រឹះស្ថានឧត្ដមសិក្សានៅជុំវិញពិភពលោក តែងខិតខំប្រឹងប្រែងបញ្ចូលធាតុអន្តរជាតិ ទៅក្នុងផ្នែកសំខាន់ៗនៃការធ្វើប្រតិបត្តិការក្នុងស្ថាប័នរបស់ខ្លួន។

## បរិបទកម្ពុជា

ទំនើបកម្មប្រព័ន្ធអប់រំកម្រិតឧត្ដមសិក្សានៅកម្ពុជា ត្រូវបានធ្វើឡើងជាលើកដំបូង ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ នៅពេលដែលភាគីបារាំង បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធអប់រំបែបបស្ចិមប្រទេស ជំនួសឱ្យប្រព័ន្ធដើមបែបប្រពៃណីរបស់កម្ពុជា។ ចាប់តាំងពីពេលនោះមក ប្រព័ន្ធអប់រំកម្រិតឧត្ដមសិក្សានៅកម្ពុជា បានឆ្លងកាត់ការផ្លាស់ប្ដូរជាច្រើន ដោយទទួលរងឥទ្ធិពលពីរបបអាណានិគមនិយមបារាំង សង្គមនិយមបែបព្រះពុទ្ធសាសនា សាធារណរដ្ឋនិយម កុម្មុយនិស្ដម៉ៅនិយម កុម្មុយនិស្ដវៀតណាមនិយម អំណាចផ្ដាច់ការនិយម អាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិ និងលទ្ធិប្រជាធិបតេយ្យបែបកូនកាត់ (Chet and Un 2019; Sam, Zain and Jamil 2012)។ គេអាចនិយាយថា ឥទ្ធិពលបរទេសទាំងនេះ បានរួមចំណែកយ៉ាងធំធេងដល់ការស្ដារនីតិសម្បទា និងការអភិវឌ្ឍឧត្ដមសិក្សានៅកម្ពុជា។ ក៏ប៉ុន្តែ ការគិតបែបនេះ គឺមិនមានភាពសមស្របនៅក្នុងបរិបទកម្ពុជាបច្ចុប្បន្នឡើយ ដោយហេតុថាជំនួយអភិវឌ្ឍន៍ទាំងនោះ អាចនឹងធ្វើឱ្យមានអតុល្យភាពរវាងធាតុដែលមានលក្ខណៈក្នុងស្រុក និងធាតុអន្តរជាតិនៅក្នុងឧត្ដមសិក្សា។ ជាលទ្ធផល វានឹងជះឥទ្ធិពលដល់ស្វ័យភាពស្ថាប័ន ការប្រើប្រាស់ភាសាដើម និងភាពពាក់ព័ន្ធរវាងមាតិកាបង្រៀននិងរៀន និងទីផ្សារការងារ (Leng 2013)។ ទោះជាយ៉ាងនេះក្ដី គ្រឹះស្ថានឧត្ដមសិក្សាកម្ពុជានៅតែប្រើប្រាស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសម្រួលដល់ការអភិវឌ្ឍស្ថាប័នរបស់ខ្លួន ព្រោះដំណើរការនេះ ត្រូវបានគេដឹងថា កំពុងជួយដល់ស្ថាប័នអប់រំឱ្យទទួលបានស្តង់ដារ កម្មវិធីសិក្សាអន្តរជាតិ បង្កើតកម្មវិធីសិក្សាប្រកបដោយភាពច្នៃប្រតិដ្ឋ បង្កើតនិងទទួលបានចំណេះដឹងនិងបច្ចេកវិទ្យាថ្មីៗ និងអភិវឌ្ឍ

---

អត្ថបទនេះរៀបរៀងដោយលោកស្រី តឹក មុយទៀង អ្នកស្រាវជ្រាវ នៅមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំនៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Tek Muytieng. 2021. “Faculty Engagement in the Internationalisation of Higher Education: A Literature Review.” Cambodia Development Review 25 (2): 1–7។

ការសិក្សានេះ ជាផ្នែកមួយនៃកម្មវិធីសហការជាដៃគូរយៈពេលបីឆ្នាំ រវាងវិទ្យាស្ថាន CDRI និងអង្គការមូលនិធីអាស៊ី ហៅថា "ថ្នាលឧត្ដមចំណេះ៖ ការលើកកម្ពស់នវានុវត្តន៍ក្នុងឧត្ដមសិក្សានៅកម្ពុជា"។ អ្នកនិពន្ធ សូមថ្លែងអំណរគុណដល់ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុតាមរយៈគម្រោងពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជារបស់អង្គការមូលនិធិអាស៊ី។

សមត្ថភាពធនធានមនុស្ស (Chet and Un 2019; Yun 2014)។ ជាងនេះទៅទៀត ការធ្វើអន្តរជាតូបនីយកម្មកម្មវិធីសិក្សា ត្រូវបានគេចាត់ទុកថា ជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយក្នុងការធ្វើឱ្យនិស្សិត ជាពិសេស អ្នកដែលមិនមានលទ្ធភាពចេញទៅក្រៅប្រទេស យល់ដឹង និងស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីខ្លឹមសារទាក់ទងនឹងអន្តរជាតិ ដើម្បីអភិវឌ្ឍជំនាញដែលចាំបាច់សម្រាប់ការប្រកួតប្រជែងទីផ្សារការងារនៅក្នុងតំបន់ និងពិភពលោក (Dash 2017)។ ដូច្នេះយើងត្រូវការជាចាំបាច់នូវកម្មវិធីសិក្សាកម្រិតអន្តរជាតិជាច្រើនទៀត ដើម្បីអប់រំនិងបណ្ដុះបណ្ដាលកម្លាំងពលកម្មសម្រាប់ពិភពលោក ដែលមានវប្បធម៌ចម្រុះពោរពេញទៅដោយភាពប្រទាក់ក្រឡាគ្នានេះ។ យ៉ាងណាមិញ ការស្រាវជ្រាវមុនៗ បានបង្ហាញថា អន្តរជាតូបនីយកម្មឧត្តមសិក្សានៅកម្ពុជា ស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយទេ (Chet 2006; Hill, Hell and Cauter 2021; Yun 2014) ហើយសកម្មភាពដែលយើងឃើញភាគច្រើន គឺមានតែការចល័តនិស្សិត និងបុគ្គលិកប៉ុណ្ណោះ រីឯសកម្មភាពផ្សេងៗទៀត ដូចជាការជ្រើសរើសនិងទទួលនិស្សិតបរទេស គឺនៅមានតិចតួចនៅឡើយ (Chet 2006; Dash 2017)។ បើនិយាយពីឯកសារគោលនយោបាយវិញ ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាជាច្រើន ត្រូវបានធ្វើឡើងដើម្បីដោះស្រាយបញ្ហាដែលកើតមាននៅក្នុងការអប់រំកម្រិតឧត្តមសិក្សា ប៉ុន្តែ មានតែឯកសារមួយប៉ុណ្ណោះ ដែលបាននិយាយជាក់លាក់ពីបញ្ហាអន្តរជាតូបនីយកម្មឧត្តមសិក្សានេះ នោះគឺ ផែនទីបង្ហាញផ្លូវឧត្តមសិក្សាឆ្នាំ២០១៧-២០៣០។ ផែនទីបង្ហាញផ្លូវនេះ បានកំណត់សូចនាករសំខាន់ៗចំនួន ៣ ដើម្បីឱ្យកម្ពុជា អាចជំរុញការចូលរួមជាអន្តរជាតិរបស់គ្រឹះស្ថានឧត្តមសិក្សា និងធ្វើការរៀបចំវិស័យឧត្តមសិក្សារបស់ខ្លួនសម្រាប់សមាហរណកម្មតំបន់ និងសកលលោក។ សូចនាករទាំងនោះ រួមមាន៖ ១) បង្កើនចល័តភាព (ចេញ-ចូលប្រទេស) របស់និស្សិត និងសមាជិកមហាវិទ្យាល័យ ២) លើកកម្ពស់ចល័តភាពកម្មវិធី និងស្ថាប័នអប់រំ និង ៣) ធ្វើឱ្យកម្មវិធីសិក្សាមានស្តង់ដាលក្ខណៈតំបន់ និងអន្តរជាតិ (MoEYS 2017, 8)។ ទោះជាយ៉ាងនេះក្តី អន្តរជាតូបនីយកម្មនេះ មិនត្រូវបានមនុស្សគ្រប់គ្នាយល់ច្បាស់នោះទេ ហើយដំណើរការក្នុងការសម្រេចបានសមិទ្ធផលនីមួយៗរបស់វា ក៏តែងតែមានភាពរដិបរដុបផងដែរ។ ហេតុនេះហើយ គ្រឹះស្ថានឧត្តមសិក្សា បានជ្រើសយកវិធីសាស្ត្រផ្សេងៗគ្នា ដើម្បីអនុវត្តអន្តរជាតូបនីយកម្មនៅក្នុងស្ថាប័នរបស់ខ្លួន។ ក្នុងនោះ អ្នកអនុវត្តមួយចំនួនយល់ថា អន្តរជាតូបនីយកម្មសំដៅលើសកម្មភាពទាំងឡាយណា ដែលជួយបង្កើនគុណភាពបង្រៀននិងរៀន និងពង្រីកកេរ្តិ៍ឈ្មោះរបស់សាកលវិទ្យាល័យ ឧទាហរណ៍ ការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាជាប្រចាំនិងធ្វើឱ្យមានការទទួលស្គាល់ជាអន្តរជាតិ ការប្រើប្រាស់ភាសាអង់គ្លេសជាមធ្យោបាយក្នុងការបង្រៀននិងរៀន ការធ្វើកិច្ចសហការស្រាវជ្រាវជាមួយដៃគូបរទេស និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន។ រីឯអ្នកមួយចំនួនទៀត ចាត់ទុកអន្តរជាតូបនីយកម្ម ជាមធ្យោបាយមួយក្នុងការបង្កើនការយល់ដឹងរបស់ និស្សិត និងបុគ្គលិក ពីអន្តរវប្បធម៌ ដែលអាចសម្រេចបានតាមរយៈកម្មវិធីផ្លាស់ប្តូរនិស្សិត និងបុគ្គលិក (Tek and Leng 2017; Yun 2014)។ ចំពោះកម្មវិធីអប់រំសញ្ញាបត្រទ្វេ កម្មវិធីអប់រំឆ្លងប្រទេស និងការបង្កើតសាខាគ្រឹះស្ថានឧត្តមសិក្សានៅក្រៅប្រទេស នៅមានកម្រិតតិចតួចណាស់នៅក្នុងបរិបទកម្ពុជា។

ទោះបីជាមានការស្រាវជ្រាវជាច្រើន ត្រូវបានធ្វើឡើងលើប្រធានបទ ទាក់ទងនឹងអន្តរជាតូបនីយកម្មឧត្តមសិក្សាកម្ពុជាក្តី ការសិក្សាអំពីតួនាទីជាក់លាក់ និងការចូលរួមរបស់សមាជិកមហាវិទ្យាល័យ (បុគ្គលិកបង្រៀននិងស្រាវជ្រាវ) ក្នុងបរិបទបែបនេះនៅមានកម្រិតនៅឡើយ។ សមាជិកមហាវិទ្យាល័យ ត្រូវបានគេដឹងថា មានឥទ្ធិពលយ៉ាងខ្លាំងលើការបំពេញបេសកកម្មសាកលវិទ្យាល័យ (ការបង្រៀន ការស្រាវជ្រាវ និងសេវាកម្មសហគមន៍) ដោយសារពួកគេជាអ្នកអនុវត្តផ្ទាល់ ជាពិសេសក្នុងការអភិវឌ្ឍខ្លឹមសារកម្មវិធីសិក្សា ការស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិនានា។ ហេតុនេះហើយ អត្ថបទនេះ បានពិនិត្យមើលលើឯកសារស្រាវជ្រាវ ពាក់ព័ន្ធនឹងការចូលរួមរបស់សមាជិកមហាវិទ្យាល័យក្នុងការធ្វើអន្តរជាតូបនីយកម្ម ដើម្បីធ្វើការវិភាគពីទម្រង់នៃការចូលរួម និងកត្តាដែលជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់ពួកគេក្នុងការចូលរួមក្នុងសកម្មភាពទាំងនោះ។

អត្ថបទនេះ ចាប់ផ្តើមដោយធ្វើការពិពណ៌នាពីទិដ្ឋភាពសង្ខេបអំពីការវិវត្តថ្មីៗ នៃអន្តរជាតូបនីយកម្មឧត្តមសិក្សានៅលើសកលលោក រួចបង្រួមមកក្នុងបរិបទកម្ពុជា។ បន្ទាប់មកអត្ថបទនេះបង្ហាញពីទម្រង់ផ្សេងៗ នៃការចូលរួមរបស់សមាជិកមហាវិទ្យាល័យក្នុងសកម្មភាពអន្តរជាតិ និងពិនិត្យមើលលើកត្តា និងយន្តការនានា ដែលជួយលើកទឹកចិត្តសមាជិកមហាវិទ្យាល័យឱ្យមានការចូលរួមយ៉ាងសកម្ម ក្នុងដំណើរការអនុវត្តអន្តរជាតូបនីយកម្ម រួចអត្ថបទនេះ បញ្ចប់ដោយមានការពិភាក្សាអំពីគំនិត ឬផែនការដាក់ចេញ សម្រាប់ពិចារណាក្នុងការអភិវឌ្ឍអនុវិស័យឧត្តមសិក្សារបស់កម្ពុជា។ ការស្រាវជ្រាវបន្ថែម ក៏បានស្នើឡើងផងដែរនៅចុងបញ្ចប់នៃអត្ថបទនេះ។

## ទម្រង់នៃការចូលរួម

សមាជិកមហាវិទ្យាល័យ បានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា ហើយការចាត់តាំងឱ្យពួកគេចូលរួមអនុវត្តសកម្មភាពអ្វីមួយនោះ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់កម្រិតនៃការចូលរួមសកម្មរបស់ពួកគេ។ ក៏ប៉ុន្តែ ពុំសូវមានការស្រាវជ្រាវច្រើនឡើយ ដែលផ្តោតសំខាន់លើការចូលរួមរបស់សមាជិកមហាវិទ្យាល័យ ជាពិសេស នៅក្នុងកិច្ចការងារអនុវត្តសកម្មភាពអន្តរជាតូបនីយកម្មឧត្តមសិក្សា (Childress 2010; Finkelstein, Walker and Chen 2013; Friesen 2013; Stohl 2007)។ តាមរយៈការបង្រៀននិងការស្រាវជ្រាវអន្តរជាតិ ការបោះពុម្ពផ្សាយ និងចូលរួមវាយតម្លៃអត្ថបទស្រាវជ្រាវ សមាជិកភាពក្នុងបណ្តាញអ្នកស្រាវជ្រាវអន្តរជាតិ និងការចូលរួមអនុវត្តគម្រោងអភិវឌ្ឍន៍អន្តរជាតិនានា សមាជិកមហាវិទ្យាល័យទទួលបានឱកាសជាច្រើនក្នុងការស្វែងយល់ពីពិភពលោក និងបាននាំយកចំណេះដឹងនិងបទពិសោធន៍ទាំងនោះត្រឡប់មកវិញ ដើម្បីចែករំលែកជូនដល់និស្សិត និងមិត្តរួមការងាររបស់ខ្លួន។ Childress (2010) ក៏បាន

ឆ្លុះបញ្ចាំងពីគំនិតនេះផងដែរ នៅពេលដែលគាត់បានចង្អុលបង្ហាញយ៉ាងច្បាស់ ពីឥទ្ធិពលផ្ទាល់ដែលសមាជិកមហាវិទ្យាល័យមានលើការបង្រៀន ការស្រាវជ្រាវ និងការផ្តល់សេវាកម្មសហគមន៍ ពីព្រោះពួកគេបានចូលរួមយ៉ាងសស្រាក់សស្រាំ ក្នុងការបង្កើតកម្មវិធីសិក្សា ការអភិវឌ្ឍ និងអនុវត្តការស្រាវជ្រាវជាមួយដៃគូបរទេស និងការអនុវត្តគម្រោងអភិវឌ្ឍន៍នានា។ នៅពេលដែលមានសិទ្ធិ និងអំណាចទាំងនេះ ពួកគេអាចសម្រេចចិត្តបានថាតើគួរបញ្ចូលធាតុអន្តរជាតិ ធាតុអន្តរវប្បធម៌ និងធាតុជាសាកលណាខ្លះទៅក្នុងកម្មវិធីសិក្សា គម្រោងស្រាវជ្រាវ និងសេវាកម្មសហគមន៍ ឬ តើគួរចូលរួមក្នុងដំណើរការអន្តរជាតូបនីយកម្មសាកលវិទ្យាល័យរបស់ពួកគេដែរឬទេ? ទាក់ទងនឹងការចូលរួមនេះផងដែរ Knight (1994) បានកំណត់សកម្មភាព និងសេវាកម្មសិក្សាមួយចំនួន ដែលបាននឹងកំពុងអនុវត្ត ឬគួរយកមកពិចារណាសម្រាប់ការអភិវឌ្ឍ និងការអនុវត្តអន្តរជាតូបនីយកម្មឧត្តមសិក្សា។ សកម្មភាពទាំងនោះ រួមមាន ការអភិវឌ្ឍកម្មវិធីសិក្សា ការផ្តល់ឱកាសឱ្យនិស្សិតស្វែងយល់ពីអន្តរជាតិ ការផ្តល់ការប្រឹក្សាយោបល់ទៅដល់និស្សិតបរទេស កម្មវិធីផ្លាស់ប្តូរ (និស្សិតនិងបុគ្គលិក) វគ្គសិក្សាភាសាបរទេស គម្រោងអភិវឌ្ឍន៍អន្តរជាតិ កិច្ចព្រមព្រៀងភាពជាដៃគូអន្តរជាតិ កិច្ចសហការស្រាវជ្រាវជាមួយដៃគូបរទេស កម្មវិធីសិក្សាលើប្រធានបទ ឬវិស័យនានាទាក់ទងនឹងអន្តរជាតិ កម្មវិធីបណ្តុះបណ្តាលអំពីវប្បធម៌ សកម្មភាពក្រៅម៉ោងសិក្សា និងសេវាកម្មផ្សេងៗទៀតដែលមានលក្ខណៈអន្តរជាតិ។ ទាំងអស់នេះទាមទារឱ្យមានការចូលរួមយ៉ាងសកម្ម ពីសមាជិកមហាវិទ្យាល័យ។ នៅជ្រុងម្ខាងទៀត សកម្មភាពអន្តរជាតិរបស់សមាជិកមហាវិទ្យាល័យ ត្រូវបានបែងចែកជា ៤ ប្រភេទជាក់លាក់ គឺការស្រាវជ្រាវនិងការបង្រៀន ការអភិវឌ្ឍកម្មវិធីសិក្សា កម្មវិធីអប់រំនៅក្រៅប្រទេស និងផ្នែកដទៃៗទៀត ដូចជា បណ្តាញអតីតនិស្សិត ភាពជាដៃគូអន្តរជាតិ កម្មវិធីអប់រំសញ្ញាបត្រទ្វេ និងសមាជិកភាពក្នុងគណៈកម្មាធិការស្រាវជ្រាវអន្តរជាតិ (Dewey and Duff 2009)។ បន្ថែមពីនេះ Beatty (2013) បានផ្តល់ព័ត៌មានលម្អិតពីប្រភេទនីមួយៗ ដោយបង្ហាញថា សកម្មភាពជាច្រើន អាចចាត់ទុកជាទម្រង់នៃការចូលរួមកិច្ចការអន្តរជាតិរបស់សមាជិកមហាវិទ្យាល័យ។ សកម្មភាពទាំងនោះ រួមបញ្ចូលទាំងការធ្វើអន្តរជាតូបនីយកម្មកម្មវិធីសិក្សា តាមរយៈការប្រើប្រាស់និស្សិតបរទេសជាធនធានសិក្សា ការបញ្ចូលបញ្ហាដែលកើតមាននៅក្នុងសកលលោកទៅក្នុងកម្មវិធីសិក្សា ការធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវនៅក្នុងសន្និសីទអន្តរជាតិ ការចូលរួមវាយតម្លៃការស្រាវជ្រាវ និងបោះពុម្ពផ្សាយអត្ថបទនៅក្នុងទិនានុប្បវត្តិអន្តរជាតិ ការដឹកនាំនិស្សិតក្នុងដំណើរទស្សនកិច្ចក្រៅប្រទេស ការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលអន្តរវប្បធម៌ និងអន្តរជាតិ និងការអភិវឌ្ឍវិជ្ជាជីវៈផ្សេងៗទៀត ដូចជា ការចូលរួមជាគណៈកម្មាធិការអនុវត្តសកម្មភាពអន្តរជាតូបនីយកម្ម ឬជាសមាជិកក្នុងសមាគមអន្តរជាតិណាមួយ។ ទោះយ៉ាងណាការជំរុញឱ្យគ្រូបង្រៀន និងអ្នកស្រាវជ្រាវ ចូលរួមក្នុងសកម្មភាពអន្តរជាតូបនីយកម្ម អាចជារឿងលំបាក ពីព្រោះក្រុមសមាជិកមហាវិទ្យាល័យមួយចំនួន បានយល់ឃើញថា សកម្មភាពទាំងនេះជាការងារបន្ថែម ហើយពួកគេមិនមានឆន្ទៈចូលរួមនោះទេ ប្រសិនបើគ្មានរង្វាន់លើកទឹកចិត្ត និងការណែនាំនិងគាំទ្រគ្រប់គ្រាន់ពីស្ថាប័ន (Beatty 2013; Childress 2010; Clarke and Yang 2019; Dewey and Duff 2009; Friesen 2013)។ សូម្បីតែអ្នកដែលមានការតាំងចិត្តខ្ពស់ក្នុងការធ្វើឱ្យសកម្មភាពអន្តរជាតូបនីយកម្មដើរទៅមុខ ក៏មិនអាចសម្រេចបានលទ្ធផលអ្វីជាដុំកំភួនដែរ។

## កត្តាជះឥទ្ធិពល

ការស្រាវជ្រាវមួយចំនួន បានបោះពុម្ពផ្សាយរៀបរាប់ពីហេតុផលចូលរួមអនុវត្តអន្តរជាតូបនីយកម្ម របស់សមាជិកមហាវិទ្យាល័យ។ ឯកសារស្រាវជ្រាវមួយក្នុងចំណោមការសិក្សាដំបូងៗ នៅក្នុងប្រធានបទនេះ គឺរបស់ Blackburn and Lawrence (1995) ដោយក្នុងការសិក្សានោះ ពួកគេបានរកឃើញកត្តាចំនួនពីរកំណត់ហេតុផលនៃការចូលរួមនេះ (រូបភាពទី១)។ ទីមួយ គឺ "ចំណេះដឹងអំពីខ្លួនឯង" (self-knowledge) ដែលជាប្រភេទនៃការវាយតម្លៃសមត្ថភាពផ្ទាល់ខ្លួនមួយចាំបាច់ ដើម្បីសម្រេចបាននូវកិច្ចការ ឬគោលដៅជាក់លាក់ ហើយវាត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធ ជាមួយនឹងការវាយតម្លៃការអនុវត្តការងាររបស់សមាជិកមហាវិទ្យាល័យ។ ក្នុងនោះដែរ វារួមបញ្ចូលទាំងចំណាប់អារម្មណ៍និងចំណង់ចំណូលចិត្ត ការប្តេជ្ញាចិត្ត ការជឿជាក់លើខ្លួនឯង អាកប្បកិរិយា និងទំនោរក្នុងការធ្វើអ្វីមួយ។ សមាសធាតុទាំងនោះ បានទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីកត្តាប្រជាសាស្ត្រនិងសង្គម (ឧទាហរណ៍ អាយុ ភេទ ជនជាតិ បទពិសោធន៍សិក្សានៅក្រៅប្រទេស) និងកត្តាអាជីព (ឧទាហរណ៍ ឋានៈ អាយុការងារ វិស័យឯកទេស និងប្រភេទស្ថាប័ន)។ ទី២ គឺ "ចំណេះដឹងសង្គម" (social knowledge) ដែលមានធាតុផ្សំ ដូចជាការយល់ឃើញរបស់បុគ្គលម្នាក់ៗ ចំពោះបរិយាកាសសង្គម/ការងាររបស់ខ្លួនជាពិសេស ការគិតរបស់ពួកគេទៅលើអាទិភាព គុណតម្លៃ និងវប្បធម៌ស្ថាប័ន និងសហការីភាព។ ករណីសង្គមពិសេសផ្សេងទៀត ដូចជា អាពាហ៍ពិពាហ៍ និងមាតុភាព ក៏ត្រូវបានយកមកវិភាគផងដែរ នៅក្នុងក្របខ័ណ្ឌនៃការសម្រេចចិត្ត និងឥរិយាបថរបស់សមាជិកមហាវិទ្យាល័យរបស់ Blackburn and Lawrence (1995)។

ចាប់តាំងពីពេលនោះមក ការសិក្សាមួយចំនួនទៀត ត្រូវបានអនុវត្តដើម្បីធ្វើតេស្តលើក្របខ័ណ្ឌនេះ។ ឧទាហរណ៍ Finkelstein et al. (2013) បានបញ្ជាក់ថា ទាំងចំណេះដឹងសង្គម និងចំណេះដឹងអំពីខ្លួនឯង គឺជាអថេរគន្លឹះសម្រាប់ព្យាករណ៍ពីការចូលរួមរបស់សមាជិកមហាវិទ្យាល័យក្នុងការស្រាវជ្រាវ ដែលមានលក្ខណៈអន្តរជាតិ។ ការយល់ឃើញចំពោះលក្ខខ័ណ្ឌការងារ គឺជាចំណុចសំខាន់មួយ ពីព្រោះការសិក្សានេះ បានរកឃើញថា អ្នកដែលធ្វើការនៅក្នុងស្ថាប័នដែលសកម្មភាពអន្តរជាតិ ត្រូវបានជំរុញដោយថ្នាក់ដឹកនាំផ្នែកសិក្សា ទំនងជាចូលរួមក្នុងគម្រោងស្រាវជ្រាវអន្តរជាតិជាង អ្នកដែលធ្វើការនៅក្នុងស្ថាប័នដឹកនាំដោយថ្នាក់ដឹកនាំផ្នែករដ្ឋបាល។ បើនិយាយពីចំណេះដឹងអំពីខ្លួនឯងវិញ ចំណាប់អារម្មណ៍ និងជម្រើសតួនាទី បានរួមចំណែកយ៉ាងខ្លាំងដល់កិច្ចសហការស្រាវជ្រាវអន្តរជាតិ ព្រោះកិច្ចខិតខំប្រឹងប្រែងក្នុង

រូបភាពទី១៖ ក្របខ័ណ្ឌនៃការសម្រេចចិត្ត និងឥរិយាបថរបស់សមាជិកមហាវិទ្យាល័យ




ចំណាំ៖ ព្រួញពណ៌ក្រហម តំណាងឱ្យឥទ្ធិពលខ្លាំង រីឯពណ៌ខ្មៅ បង្ហាញពីកម្រិតឥទ្ធិពលទាប។

ប្រភព៖ Blackburn and Lawrence (1995)

ការបំពេញការងារអ្វីមួយ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងចំណាប់អារម្មណ៍ និងទំនួលខុសត្រូវការងារដែលសមាជិកមហាវិទ្យាល័យមាន។ លទ្ធផលស្រាវជ្រាវទាំងនេះ ត្រូវបានគាំទ្រជាថ្មីម្តងទៀតដោយ Nyangau (2020) នៅពេលដែលគាត់បានរកឃើញថា ការជឿទុកចិត្តលើខ្លួនឯង និងអាកប្បកិរិយាចំពោះបរិយាកាសការងារអំណោយផល មានឥទ្ធិពលយ៉ាងខ្លាំងទៅលើការសម្រេចចិត្តចូលរួម របស់សមាជិកមហាវិទ្យាល័យក្នុងដំណើរការអនុវត្តអន្តរជាតូបនីយកម្ម។ ដូច្នេះ សមត្ថភាពនិងការយល់ឃើញវិជ្ជមានអំពីបរិយាកាសសង្គម ហាក់ដូចជាមានភាពសំខាន់ណាស់ ក្នុងការជំរុញឱ្យសមាជិកមហាវិទ្យាល័យចូលរួមដំណើរឆ្ពោះ ទៅរកការធ្វើអន្តរជាតូបនីយកម្មឧត្តមសិក្សាដ៏ជោគជ័យមួយ។

កត្តាប្រជាសាស្ត្រនិងសង្គម និងកត្តាអាជីព ក៏គួរត្រូវបានលើកឡើង ជាកត្តារួមចំណែកដល់ការជំរុញឱ្យមានការចូលរួមជាអន្តរជាតិរបស់សមាជិកមហាវិទ្យាល័យផងដែរ។ Vabø et al. (2014) បានចង្អុលទៅកាន់ភាពខុសគ្នានៅក្នុងការចូលរួមកិច្ចការអន្តរជាតិរវាង សមាជិកមហាវិទ្យាល័យបុរស និងស្ត្រី ដោយបានបញ្ជាក់ថា សមាជិកមហាវិទ្យាល័យភេទប្រុស មានភាគរយខ្ពស់ក្នុងការចូលរួមគម្រោង ដែលតម្រូវឱ្យមានការធ្វើដំណើរឆ្លងប្រទេស ចំណែកឯសមភាគីស្រីរបស់ពួកគេ មានភាពសកម្មក្នុងការអនុវត្តសកម្មភាពអន្តរជាតូបនីយកម្មក្នុងស្រុក (at-home)។ ការផ្តល់ឱកាសឱ្យស្វែងយល់ពីអន្តរជាតិ ក៏ត្រូវបានកំណត់ថា ជាកត្តាមួយជួយជំរុញឱ្យសមាជិកមហាវិទ្យាល័យ ចូលរួមក្នុងសកម្មភាពអន្តរជាតូបនីយកម្មផងដែរ ដោយសារតែនៅពេលដែលពួកគេមានបទពិសោធន៍ក្រៅប្រទេសកាន់តែច្រើន នោះកម្រិតនៃការចូលរួមរបស់ពួកគេ នឹងមានកាន់តែខ្ពស់។ ជាមួយនឹងឱកាសបែបនេះ ពួកគេ ក៏ទំនងជាបានអភិវឌ្ឍអាកប្បកិរិយាវិជ្ជមាន និងបង្កើនជំនឿចិត្ត ក្នុងការចូលរួមអនុវត្តកិច្ចការងារនេះផងដែរ។ ជាលទ្ធផលពួកគេនឹងមានការចូលរួមសកម្មជាងមុន ក្នុងការអនុវត្តអន្តរជាតូបនីយកម្មក្នុងស្ថាប័នរបស់ខ្លួន (Calikoglu, Lee and Arslan 2020; Friesen 2013; Romani-Dias, Carneiro and Barbosa 2019; Schwietz 2006)។

ផ្ទុយពីកត្តាជំរុញពីខាងក្នុងដែលបានរៀបរាប់ខាងលើ Knight (1994, 7) បានរំឭកយើងឱ្យផ្តល់សារៈសំខាន់ទៅលើកត្តាស្ថាប័នដែរ។ គាត់បានសង្កត់ធ្ងន់ថា "វា [កត្តាស្ថាប័ន] អាចអនុញ្ញាត (ឬហាមឃាត់) ដំណើរការបញ្ចូលធាតុអន្តរជាតិទៅក្នុងមុខងារចម្បងៗរបស់ស្ថាប័ន"។ ការបង្ហាញច្បាស់លាស់ពីការប្តេជ្ញាចិត្តនិងការគាំទ្រយ៉ាងពេញទំហឹង ពីថ្នាក់ដឹកនាំសាកលវិទ្យាល័យគឺសំខាន់ណាស់ ដើម្បីសម្រេចបានការងារអន្តរជាតូបនីយកម្មដោយជោគជ័យ ជាពិសេសនៅពេលដែលសកម្មភាពទាំងនោះទាមទារឱ្យមានការចូលរួមយ៉ាងសកម្ម ពីអ្នកពាក់ព័ន្ធគ្រប់រូបនៅក្នុងស្ថាប័ន (Beatty 2013; Calikoglu, Lee and Arslan 2020; Childress 2010; Li and Tu 2016; Nyangau 2020)។ នៅពេលដែលស្ថាប័នមួយ មានចក្ខុវិស័យនិងគោលបំណងច្បាស់លាស់ ស្ថាប័ននោះ អាចបង្កើតជាសកម្មភាពយុទ្ធសាស្ត្រជាក់លាក់ទាក់ទងនឹងការកៀរគរធនធាន និងការវាយតម្លៃនិងដំឡើងតំណែងបុគ្គលិក។ ទោះយ៉ាងណា គ្រឹះស្ថានឧត្តមសិក្សា គួរគប្បីប្រុងប្រយ័ត្នចំពោះភាពខុសគ្នាដែលអាចកើតមានរវាងឯកសារយុទ្ធសាស្ត្រ និងការយល់ដឹងរបស់សមាជិកមហាវិទ្យាល័យ អំពីគោលបំណងរបស់ស្ថាប័នក្នុងការអនុវត្តកិច្ចការអន្តរជាតូបនីយកម្ម។ ដើម្បីធានាបានថា ព័ត៌មានត្រឹមត្រូវត្រូវបានផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព Friesen (2013) ស្នើឱ្យមានការអនុវត្តសកម្មភាពមួយចំនួន៖ ទីមួយ គប្បីមានការប្រាស្រ័យទាក់ទងឱ្យច្បាស់លាស់ ក្នុងចំណោមបុគ្គលិកសាកលវិទ្យាល័យ អំពីដំណើរការអនុវត្តអន្តរជាតូបនីយកម្ម (អត្ថន័យ គោលបំណង និងគុណតម្លៃ)។ ទី២៖ កិច្ចសន្ទនាគួរត្រូវបានធ្វើឡើង ដើម្បីផ្តល់ឱកាសដល់ថ្នាក់ដឹកនាំ បុគ្គលិកសិក្សានិងរដ្ឋបាល និងអ្នកពាក់ព័ន្ធដទៃទៀត ចូលរួមពិភាក្សាអំពី

បញ្ហានេះ។ ជាចុងក្រោយ បរិយាកាសអំណោយផលមួយ គួរត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ការចូលរួមរបស់សមាជិកមហាវិទ្យាល័យ ក្នុងការងារអន្តរជាតូបនីយកម្មនេះ។ ការនិយាយដូច្នេះ Li and Tu (2016) បានបញ្ជាក់ថា គ្រាន់តែការធ្វើឱ្យបរិយាកាសការងារប្រសើរឡើងតែមួយមុខ (ឧទាហរណ៍ ការគាំទ្រផ្នែកសម្ភារៈ និងសង្គម) គឺមិនគ្រប់គ្រាន់នោះទេ។ ការអភិវឌ្ឍសមត្ថភាពសមាជិកមហាវិទ្យាល័យ ដូចជា ការបង្កើនជំនាញភាសាបរទេស និងពង្រីកចំណេះដឹងអន្តរវប្បធម៌ គប្បីធ្វើឡើងដើម្បីឱ្យពួកគាត់អាចចូលរួមយ៉ាងសកម្ម ឬពេលខ្លះអាចមានជាគំនិតផ្ដួចផ្ដើម ឬបង្កើតផែនការអន្តរជាតូបនីយកម្មក្នុងស្រុក និងក្រៅប្រទេសផងដែរ។

## សេចក្ដីសន្និដ្ឋាន

អត្ថបទនេះ មានគោលបំណងពិនិត្យមើលលើទម្រង់នៃការចូលរួមរបស់សមាជិកមហាវិទ្យាល័យ ក្នុងការធ្វើអន្តរជាតូបនីយកម្ម និងកត្តាជះឥទ្ធិពលដល់ការចូលរួមរបស់ពួកគេ នៅក្នុងដំណើរការនេះ។ ឯកសារស្រាវជ្រាវ បានចង្អុលបង្ហាញជាបន្តបន្ទាប់ថា សមាជិកមហាវិទ្យាល័យ បានដើរតួយ៉ាងសំខាន់ក្នុងដំណើរការអនុវត្តកិច្ចការអន្តរជាតូបនីយកម្ម ដោយសារពួកគាត់មានឥទ្ធិពលដោយផ្ទាល់ លើសកម្មភាពអន្តរជាតិភាគច្រើន ហើយចំណេះដឹងអំពីខ្លួនឯង និងចំណេះសង្គមរបស់ពួកគាត់ មានឥទ្ធិពលយ៉ាងខ្លាំងលើការសម្រេចចិត្តចូលរួមក្នុងសកម្មភាពបែបនេះ។ ការខិតខំប្រឹងប្រែងអនុវត្តកិច្ចការអន្តរជាតិរបស់ពួកគាត់ អាចមើលឃើញតាមរយៈការបង្រៀន និងនវានុវត្តន៍កម្មវិធីសិក្សា ចល័តភាពឆ្លងប្រទេស កិច្ចសហការនិងបណ្ដាញស្រាវជ្រាវអន្តរជាតិ និងការអនុវត្តគម្រោងអភិវឌ្ឍន៍នានា។

ការពិនិត្យមើលឯកសារស្រាវជ្រាវនេះ បានបង្ហាញថាចំណេះដឹងអំពីខ្លួនឯង និងការយល់ឃើញចំពោះបរិយាកាសការងារនៅក្នុងស្ថាប័ន គឺជាគន្លឹះក្នុងការជំរុញឱ្យមានការចូលរួមរបស់សមាជិកមហាវិទ្យាល័យ ក្នុងដំណើរការអន្តរជាតូបនីយកម្មឧត្តមសិក្សា។ នៅពេលដែលពួកគាត់មានទំនុកចិត្តថា ខ្លួនមានចំណេះដឹង និងជំនាញចាំបាច់គ្រប់គ្រាន់ សម្រាប់បំពេញភារកិច្ចដែលមានលក្ខណៈអន្តរជាតិ នោះពួកគាត់នឹងមានភាគរយខ្ពស់ក្នុងការប្ដេជ្ញាចិត្តបំពេញកិច្ចការទាំងអស់នោះ។ ការប្ដេជ្ញាចិត្ត និងការគាំទ្រ ដែលត្រូវបានបង្ហាញយ៉ាងច្បាស់ដោយថ្នាក់ដឹកនាំសាកលវិទ្យាល័យ ក៏ជះឥទ្ធិពលយ៉ាងខ្លាំង ដល់ការចូលរួមរបស់សមាជិកមហាវិទ្យាល័យផងដែរ ព្រោះកត្តាទាំងនេះ មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងការទទួលស្គាល់លទ្ធផលការងារ និងប្រព័ន្ធផ្ដល់រង្វាន់ការងារ។ ហេតុនេះហើយ គ្រឹះស្ថានឧត្ដមសិក្សា គប្បីពិនិត្យ និងតាមដានមើលលើតួនាទីដ៏មានឥទ្ធិពល និងជំរុញការចូលរួមរបស់សមាជិកមហាវិទ្យាល័យ ដើម្បីធានាឱ្យបាន នូវការអនុវត្តផែនការអន្តរជាតូបនីយកម្មដោយជោគជ័យ និងសម្រេចឱ្យបាននូវគោលដៅក្នុងការធ្វើឱ្យគុណភាពអប់រំមានភាពប្រសើរឡើង និងពង្រីកលទ្ធភាពទទួលបានការអប់រំកម្រិតឧត្ដមសិក្សា។ ដើម្បីបង្កើនការចូលរួមសកម្មភាពអន្តរជាតូបនីកម្ម របស់សមាជិកមហាវិទ្យាល័យ និងដើម្បីធ្វើឱ្យដំណើរការអភិវឌ្ឍអន្តរជាតូបនីយកម្មឧត្ដមសិក្សារបស់ខ្លួនមានភាពប្រសើរឡើង ជាដំបូង គ្រឹះស្ថានឧត្ដមសិក្សាកម្ពុជា គួរធានាឱ្យបានថា សមាជិកមហាវិទ្យាល័យរបស់ខ្លួនត្រូវបានបំពាក់ដោយសមត្ថភាពពេញលេញ ដើម្បីអនុវត្តកិច្ចការងារអន្តរជាតិ។ ជាទូទៅសមត្ថភាពទាំងនោះ រួមមាន ជំនាញភាសាបរទេស ចំណេះដឹងអន្តរវប្បធម៌និងជំនាញទំនាក់ទំនង និងចំណេះដឹងបច្ចេកទេស។ ប្រព័ន្ធទំនាក់ទំនងដែលមានប្រសិទ្ធិភាពមួយគួរត្រូវបានរៀបចំឡើងដើម្បីឱ្យសមាជិកមហាវិទ្យាល័យ អាចស្វែងយល់ឱ្យកាន់តែច្បាស់អំពីហេតុផលនៅពីក្រោយ និងដំណើរការអន្តរជាតូបនីយកម្មរបស់ស្ថាប័នខ្លួន។ ការលើកទឹកចិត្ត និងការដែលមានប្រព័ន្ធផ្ដល់រង្វាន់ការងារជាក់លាក់ គឺជាវិធានការបន្ថែមដើម្បីលើកទឹកចិត្តសមាជិកមហាវិទ្យាល័យ ឱ្យចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែង អនុវត្តសកម្មភាពអន្តរជាតូបនីយកម្ម។ ជាចុងក្រោយ យើងត្រូវការយន្តការប្រកបដោយប្រសិទ្ធភាពមួយក្នុងការផ្ដល់ថវិកាសម្រាប់អនុវត្តគម្រោង ក្នុងនោះ យើងគប្បីមានការចែករំលែកទំនួលខុសត្រូវថ្លៃចំណាយ មិនថា រវាងសមាជិកមហាវិទ្យាល័យ និងស្ថាប័ន ឬរវាងស្ថាប័ន និងភាគីទីបីនោះទេ ជាពិសេស ខណៈពេលដែលគ្រឹះស្ថានឧត្ដមសិក្សាកម្ពុជាភាគច្រើន តែងប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុក្នុងដំណើរការអន្តរជាតូបនីយកម្មដែលត្រូវការចំណាយខ្ពស់នេះ។

មិនតែប៉ុណ្ណោះ ការពិនិត្យឯកសារស្រាវជ្រាវនេះ បានបង្កើតចេញជាសំណួរជាច្រើនដែលត្រូវការការស្រាវជ្រាវបន្ថែម។ កង្វះឯកសារស្រាវជ្រាវ អំពីការចូលរួមរបស់សមាជិកមហាវិទ្យាល័យក្នុងដំណើរការអនុវត្តអន្តរជាតូបនីយកម្មនៅកម្ពុជា នាំឱ្យព័ត៌មានទាក់ទងនឹងប្រធានបទនេះ មានការខ្វះខាត។ ដូច្នេះការសិក្សាថ្នាក់ជាតិមួយ គួរត្រូវបានធ្វើឡើងដើម្បីកំណត់ពីបច្ចុប្បន្នភាពនៃអន្តរជាតូបនីយកម្មឧត្ដមសិក្សា ក៏ដូចជា ការចូលរួមរបស់សមាជិកមហាវិទ្យាល័យនៅក្នុងដំណើរការនេះ។ តើសមាជិកមហាវិទ្យាល័យបានចូលរួម និងត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងដំណើរការអន្តរជាតូបនីយកម្មឧត្ដមសិក្សានេះ ក្នុងទម្រង់បែបណា ក៏ជាសំណួរដែលបានលេចចេញពីការពិនិត្យឯកសារស្រាវជ្រាវនេះផងដែរ។ ជាមួយនឹងសូចនាករ ដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវឧត្ដមសិក្សាឆ្នាំ២០១៧-២០៣០ (ក្នុងនោះមានការជួយសម្រួលដល់ ចល័តភាពរបស់និស្សិតនិងសមាជិកមហាវិទ្យាល័យ ការលើកកម្ពស់កម្មវិធីអប់រំអន្តរជាតិ និងការបង្កើតសាខាគ្រឹះស្ថានឧត្ដមសិក្សានៅក្រៅប្រទេស និងការធ្វើឱ្យកម្មវិធីសិក្សាមានស្ដង់ដារអន្តរជាតិ) សំណួរសំខាន់មួយទៀតបានផុសចេញមក៖ តើសមាជិកមហាវិទ្យាល័យ មានតួនាទីអ្វីខ្លះដើម្បីសម្រេចមហិច្ឆតាអន្តរជាតូបនីយកម្មនេះបាន?

## ឯកសារយោង


Beatty, Matthew R. 2013. “Factors Influencing Faculty Participation in Internationalization at the University of Minnesota’s Schools of Nursing and Public Health: A Case Study.” PhD. diss., Minneapolis, MN: University of Minnesota.

Blackburn, Robert T., and Janet H. Lawrence. 1995. *Faculty at Work: Motivation, Expectation, Satisfaction*. Baltimore, MD: Johns Hopkins University Press.

Buckner, Elizabeth, and Sharon Stein. 2020. "What Counts as Internationalization? Deconstructing the Internationalization Imperative:" *Journal of Studies in International Education* 24 (2): 151–66. https://doi.org/10.1177/1028315319829878.

Calikoglu, Alper, Jenny J. Lee, and Hasan Arslan. 2020. "Faculty International Engagement: Examining Rationales, Strategies, and Barriers in Institutional Settings." *Journal of Studies in International Education* Advance online publication. https://doi.org/10.1177/1028315320963508.

Chet, Chealy. 2006. "Cambodia." In *Higher Education in South-East Asia,* 13–33. Bangkok: UNESCO Bangkok.

Chet, Chealy, and Leang Un. 2019. "The Internationalization of Higher Education in Cambodia." *Cambodia Journal of Basic and Applied Research* 1 (1): 6–15.

Childress, Lisa K. 2010. *The Twenty-First Century University: Developing Faculty Engagement in Internationalization.* New York: Peter Lang Publishing.

Clarke, Marie, and Linda Hui Yang. 2019. "Internationalization: Perspectives from University Faculty in the Republic of Ireland." *Journal of Studies in International Education* 25 (2): 136–51. https://doi.org/10.1177/1028315319888469.

Dash, Tapas R. 2017. "Higher Education Stakeholder Perception on Internationalization of the Curriculum." In *The Globalization of Internationalization: Emerging Voices and Perspectives,* edited by Hans de Wit, Jocelyne Gacel-Ávila, Elspeth Jones, and Nico Jooste, 194–208. New York: Routledge.

Dewey, Patricia, and Stephen Duff. 2009. "Reason before Passion: Faculty Views on Internationalization in Higher Education." *Higher Education* 58 (4): 491–504. https://doi.org/10.1007/s10734-009-9207-z.

Finkelstein, Martin J., Elaine Walker, and Rong Chen. 2013. "The American Faculty in an Age of Globalization: Predictors of Internationalization of Research Content and Professional Networks." *Higher Education* 66 (3): 325–40. https://doi.org/10.1007/s10734-012-9607-3.

Friesen, Rhonda. 2013. "Faculty Member Engagement in Canadian University Internationalization: A Consideration of Understanding, Motivations and Rationales." *Journal of Studies in International Education* 17 (3): 209–27. https://doi.org/10.1177/1028315312451132.

Hill, Christopher, Stefan Hell, and Kevin Cauter. 2021. "Internationalising Higher Education in Cambodia, Lao PDR, Myanmar, and Viet Nam: Challenges and Approaches." *Studies in Higher Education* 46 (7): 1477–91. https://doi.org/10.1080/03075079.2019.1680966.

Knight, Jane. 1994. Internationalization: Elements and Checkpoints. Ottawa: Canadian Bureau for International Education.

———. 2004. "Internationalization Remodeled: Definition, Approaches, and Rationales." *Journal of Studies in International Education* 8 (1): 5–31. https://doi.org/10.1177/1028315303260832.

Leng, Phirom. 2013. "Foreign Influence on Cambodian Higher Education since the 1990s." *Mind & Time Publications*, 1–29.

Li, Bihong, and Yangjun Tu. 2016. "Motivations of Faculty Engagement in Internationalization: A Survey in China." Higher Education 71 (1): 81–96. https://doi.org/10.1007/s10734-015-9890-x.

Ministry of Education, Youth and Sport. 2017. "Cambodia Higher Education Roadmap 2017-2030 and Beyond." Phnom Penh: MoEYS.

Nyangau, Josiah Zachary. 2020. "Faculty Engagement in Internationalization: The Role of Personal Agency Beliefs." *International Journal of Research in Education and Science* 6 (1): 74–85. https://doi.org/10.46328/ijres.v6i1.652.

Romani-Dias, Marcello, Jorge Carneiro, and Aline dos Santos Barbosa. 2019. *"Internationalization of Higher Education Institutions: The Underestimated Role of Faculty." International Journal of Educational Management* 33 (2): 300–316. https://doi.org/10.1108/IJEM-07-2017-0184.

Sam, Rany, Ahmad Nurulazam Md Zain, and Hazri Jamil. 2012. "Cambodia's Higher Education Development in Historical Perspectives (1863-2012)." *International Journal of Learning and Development* 2 (2): 224–41. https://doi.org/10.5296/ijld.v2i2.1670.

Schwietz, Michele S. 2006. "Internationalization of the Academic Profession: An Exploratory Study of Faculty Attitudes, Beliefs and Involvement at Public Universities in Pennsylvania." PhD. diss., Pittsburgh, PA: University of Pittsburgh.

Stohl, Michael. 2007. "We Have Met the Enemy and He Is Us: The Role of the Faculty in the Internationalization of Higher Education in the Coming Decade." J*ournal of Studies in International Education* 11 (3–4): 359–72. https://doi.org/10.1177/1028315307303923.

Tek, Muytieng, and Phirom Leng. 2017. "How Do Cambodian Academic Leaders Define and Perceive Higher Education Internationalization?" *Cambodia Development Review* 21 (1): 1–7.

Vabø, Agnete, Laura Elena Padilla-González, Erica Waagene, and Terje Næss. 2014. "Gender and Faculty Internationalization." In *The Internationalization of the Academy: Changes, Realities and Prospects,* edited by Futao Huang, Martin Finkelstein, and Michele Rostan, 183–205. The Changing Academy – The Changing Academic Profession in International Comparative Perspective. Dordrecht: Springer Netherlands.

Wit, Hans de, Fiona Hunter, Laura Howard, and Eva Egron-Polak. 2015. "Internationalisation of Higher Education: A Study for the European Parliament." Brussels: European Union.

Yun, Kea. 2014. "Internationalization of Higher Education in Cambodia: Perceptions, Practices, and Challenges at the Royal University of Phnom Penh." PhD. diss., Japan: Waseda University.